អង្គការខារ៉ាមកម្ពុជា

# តើធ្វើដូចម្តេចដើម្បី សុវត្ថិភាពចំណាកស្រុក?

តើពលករចំណាកស្រុក ក្រុមគ្រួសារ ឬសហគមន៍របស់ពួកគេត្រូវការជំនួយអន្តរាគមន៍ ឬស្វែងយល់ពីសេវាកម្មផ្សេងៗទៀតអ្វីខ្លះ?

☑ស្វែងរកកិច្ចអន្តរាគមន៍ដល់ពលករក្នុងករណីលក្ខខណ្ឌការងារធ្ងន់ធ្ងរ កេងប្រវ័ញ្ចកំលាំងពលកម្ម ឬការជួញដូរមនុស្ស

☑ស្វែងយល់ពីសុវត្ថិភាពចំណាកស្រុកជាមុន មុនពេលសំរេចចិត្តថាចំណាកស្រុកជាជំរើសចុងក្រោយ

☑ព័ត៌មាន/ចំងល់ ឬសេវាកកម្មផ្សេងៗទៀតរបស់អង្គការ

☞សូមមេត្តាទំនាក់ទំនងអង្គការខារ៉ាម តាមអាសយដ្ឋានៈ

ផ្ទះលេខ ១៩៣AE0 ផ្លូវត្រសក់ផ្អែម សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

សូមអគុណ!

☎ 012 961 427
☎ 012 949 914
☎ 023 218 065

## កត្តាគួរយល់ដឹងមុនពេលសម្រេចចិត្តធ្វើចំណាកស្រុក

*តើអ្នកបានត្រៀមខ្លួនហើយឬនៅ នៅពេលដែលអ្នកចង់ធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស?*

ខាងក្រោមនេះជាព័ត៌មានសំខាន់ៗ ដើម្បីជួយពលករធ្វើការសំរេចចិត្តបានត្រឹមត្រូវមុនពេលធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្រៅប្រទេសៈ

- តើវាជាជម្រើសចុងក្រោយហើយឬនៅ នៅពេលដែលអ្នកសំរេចចិត្តធ្វើចំណាកស្រុក?
- តើអ្នកបានធ្វើការពិគ្រោះយោបល់ត្រឹមត្រូវ និងម៉ត់ចត់ជាមួយក្រុមគ្រួសារ/សាច់ញាតិ អាជ្ញាធរមូលដ្ឋាន ភាគីពាក់ព័ន្ធ ព្រមទាំងស្ថាប័នដែលធ្វើការងារលើវិស័យចំណាកស្រុក និងសិទ្ធិមនុស្ស ដើម្បីទទួលបានព័ត៌មាន កាន់តែច្បាស់ពីប្រទេស ដែលអ្នកត្រូវទៅធ្វើការហើយឬនៅ?
- តើអ្នកនឹងទទួលបានផលប្រយោជន៍អ្វីខ្លះពីការធ្វើចំណាកស្រុករបស់អ្នក?
- តើអ្នកត្រូវចំណាយថវិកាអស់ប៉ុន្មានសំរាប់ការធ្វើចំណាកស្រុក? ទៅតាមមធ្យោបាយណា? ប្រើរយៈពេលអស់ប៉ុន្មានដើម្បីទៅដល់ប្រទេសទទួល?
- តើអ្នកបានស្វែងរកស្ថាប័នពាក់ព័ន្ធសម្រាប់ទំនាក់ទំនងព័ត៌មានសុវត្ថិភាពចំណាកស្រុកនិងការស្នើសុំអន្តរាគមន៍ហើយរឺនៅ?
- ចូរអ្នកគិតថា តើអ្នកអាចប្រឈមមុខបញ្ហាអ្វីខ្លះក្នុងការធ្វើចំណាកស្រុក?
- តើអ្នកបានស្វែងយល់ពីល័ក្ខខ័ណ្ឌនៃកិច្ចសន្យាហើយឬនៅ ទាក់ទងនឹងប្រភេទការងារ ដែលអ្នកនឹងត្រូវធ្វើនៅប្រទេសទទួល ម៉ោងធ្វើការងារ ប្រាក់បៀវត្សប្រចាំខែ ការឈប់សំរាក ប្រាក់ឧបត្ថម្ភបន្ថែម បទពិពណ៌នាការងារ ការទៅរកសេវាសុខភាពពេលអ្នកឈឺ រយៈពេលនៃការកាត់ប្រាក់ឈ្នួលសងដល់ក្រុមហ៊ុននិងរយៈពេលនៃកិច្ចសន្យាការងារ។ល។
- តើអ្នកបានយកទូរស័ព្ទផ្ទាល់ខ្លួន ឬរក្សាទុកលេខទូរស័ព្ទ ទីភ្នាក់ងារជ្រើសរើសពលករ អង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការងារលើវិស័យចំណាកស្រុក និងសិទ្ធិមនុស្ស ស្ថានទូតខ្មែរប្រចាំនៅប្រទេសទទួល និងស្ថាប័នពាក់ព័ន្ធសម្រាប់ទំនាក់ទំនងជាមួយដែរឬទេ?
- តើអ្នកបានថតចម្លងឯកសារផ្សេងៗដូចជា លិខិតឆ្លងដែន កិច្ចសន្យាការងារ អាស័យដ្ឋានការងារដែលអ្នកត្រូវទៅធ្វើការនៅក្រៅប្រទេស និងឯកសារពាក់ព័ន្ធផ្សេងៗ ដោយរក្សាទុកជាមួយអ្នកឬក្រុមគ្រួសាររបស់អ្នក ហើយជៀសវាងផ្ញើទុកឯកសារទាំងនោះនៅទីភ្នាក់ងារជ្រើសរើសពលករដែររឺទេ?
- ចូរចងចាំថារាល់ឯកសារពាក់ព័ន្ធដែលអ្នក ឬ ក្រុមគ្រួសាររបស់អ្នក បានចុះហត្ថលេខាជាមួយទីភ្នាក់ងារជ្រើសរើសពលករ អ្នកមានសិទ្ធិទទួលបាននូវច្បាប់ថតចំលងដើម្បីរក្សាទុកជាភស្តុតាងនិងឯកសារកាលប្បវត្តិផងដែរ។
- ប្រការដែលសំខាន់ផងដែរនោះគឺ អ្នកត្រូវសាកសួរព័ត៌មានពីអ្នកដែលមានបទពិសោធន៍ ធ្លាប់ទៅធ្វើការនៅក្រៅប្រទេស ទាំងអ្នកជួបបទពិសោធន៍ល្អ និងអាក្រក់ដើម្បីជាប្រទីបក្នុងការបំភ្លឺផ្លូវដល់អ្នកផងដែរ។



*សកម្មភាពផ្សព្វផ្សាយសុវត្ថិភាពចំណាកស្រុកដល់ប្រជាពលរដ្ឋខេត្តកោះកុងឆ្នាំ២០១៣*

**ទៀត អោយបានកាន់តែច្បាស់ ក្នុងការធ្វើចំណាកស្រុក ប្រកបដោយភាពវៃឆ្លាត និង សុវត្ថិភាព៖**

- តើក្រុមហ៊ុន/ភ្នាក់ងារជ្រើសរើសពលកររបស់អ្នក ស្របច្បាប់ដែរឬទេ?ប្រសិនបើស្របច្បាប់តើខ្ញុំអាចសុំ ឯកសារច្បាប់ថតចម្លង ឬអាជ្ញាប័ណ្ណដែលអនុញ្ញាតដោយរដ្ឋាភិបាលដើម្បីពិនិត្យមើលផងបានដែរឬទេ?

- តើខ្ញុំត្រូវបំពេញបែបបទ ឬលក្ខខណ្ឌការងារដូចម្តេចខ្លះ ដើម្បីអាចទៅធ្វើការងារនៅក្រៅប្រទេសបាន?
- តើខ្ញុំអាចសុំឯកសារពាក់ព័ន្ធផ្សេងៗ (ឧទាហរណ៍ដូចជា កិច្ចសន្យាការងារ កិច្ចសន្យាខ្ចីប្រាក់ កិច្ចសន្យាធានា លិខិតបញ្ជាក់លទ្ធផលធ្វើតេស្តឈាម ។ល។)បានដែរឬទេ?
- តើខ្ញុំត្រូវចំណាយថវិកាអស់ប៉ុន្មាន ដើម្បីអាចទៅធ្វើការងារនៅក្រៅប្រទេសបាន?
- តើខ្ញុំអាចទទួលបានប្រាក់ឈ្នួលឬប្រាក់បៀវត្សប៉ុន្មានក្នុងមួយខែពីក្រុមហ៊ុន? តើក្រុមហ៊ុនកាត់ប្រាក់ឈ្នួល/បៀវត្សរបស់ខ្ញុំ ប៉ុន្មានខែចំពោះប្រាក់ដែលអោយខ្ញុំខ្ចី រួមទាំងការចំណាយផ្សេងៗដូចជា លិខិតឆ្លងដែន ពិនិត្យសុខភាព ការស្នាក់នៅឬការហូបចុកនៅក្នុងក្រុមហ៊ុន ។ល។?
- តើខ្ញុំត្រូវរង់ចាំអស់រយៈពេលប៉ុន្មាន មុននឹងអាចទៅធ្វើការងារនៅក្រៅប្រទេសបាន?
- នៅពេលដែលខ្ញុំឈឺ តើនរណាជាអ្នកចេញថ្លៃចំណាយសម្រាប់ការព្យាបាល ឬមួយក៏ខ្ញុំត្រូវចេញ ដោយខ្លួនឯង សម្រាប់ថ្លៃចំណាយការព្យាបាល?
- ចុះប្រសិន បើខ្ញុំមិនពេញចិត្តនឹងដំណោះស្រាយចំពោះវិវាទនោះ តើខ្ញុំអាចប្តឹងទៅស្ថាប័នពាក់ព័ន្ធណាផ្សេងទៀត ដើម្បីជួយអន្តរាគមន៍បានដែរឬទេ?
- ប្រសិនបើខ្ញុំធ្វើការមិនចប់កិច្ចសន្យាការងាររយៈពេល២ឆ្នាំ ដោយសារមូលហេតុផ្សេងៗដូចជា ឈឺ ឬក៏លក្ខខណ្ឌការងារធ្ងន់ធ្ងរ ឬការរំលោភបំពានផ្សេងៗដែលអាចកើតឡើង តើនរណាជាអ្នក ទទួលខុសត្រូវក្នុងការដោះស្រាយ ជាពិសេសការបញ្ជូនខ្ញុំត្រឡប់មកប្រទេសកំណើតវិញ?
- តើខ្ញុំអាចទូរស័ព្ទទំនាក់ទំនងមកក្រុមគ្រួសារប៉ុន្មានដងក្នុង១ឆ្នាំ នៅពេលដែលខ្ញុំនៅក្រៅប្រទេស ?
- នៅពេលដែលខ្ញុំចូលមកស្នាក់នៅក្នុងមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុន តើខ្ញុំអាចទៅលេងផ្ទះបានដែរឬទេ?ប្រសិនបើបាន តើខ្ញុំអាចទៅលេងផ្ទះបានប៉ុន្មានដង?
- តើខ្ញុំត្រូវធ្វើការងារអ្វីខ្លះ? ប៉ុន្មានម៉ោងក្នុងមួយថ្ងៃ? ហើយមានប្រាក់បន្ថែមម៉ោង និងថ្ងៃឈប់សម្រាកផ្សេងៗដែរឬទេ ក្នុងរយៈពេលនៃកិច្ចសន្យាការងារ២ឆ្នាំនៅក្រៅប្រទេស?
- ប្រសិនបើខ្ញុំមិនពេញចិត្តនឹងលក្ខខណ្ឌការងារ ឬមានវិវាទជាមួយថៅកែ តើខ្ញុំអាចប្តូរថៅកែបានដែរឬទេ?
- នៅពេលមានគ្រោះថ្នាក់ការងារកើតឡើងចំពោះខ្ញុំ តើនរណា(និយោជកនៅក្រៅប្រទេស ឬ ភ្នាក់ងារ ជ្រើសរើសពលករនៅក្រៅប្រទេស ឬភ្នាក់ងារជ្រើសរើសពលករនៅក្នុងប្រទេស ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)ជាអ្នកទទួលខុសត្រូវក្នុងការដោះស្រាយ ជាពិសេស គឺការផ្តល់ប្រាក់សំណងចំពោះគ្រោះថ្នាក់ការងារ?
- តើខ្ញុំអាចដឹងពីអាស័យដ្ឋានដែលខ្ញុំត្រូវស្នាក់នៅឬអាស័យដ្ឋានដែលខ្ញុំត្រូវទៅធ្វើការងារនៅក្រៅប្រទេសជាមុនបានដែរឬទេ?
- តើខ្ញុំត្រូវធ្វើដូចម្តេច នៅពេលថៅកែបង្ខំខ្ញុំឲ្យបន្តកិច្ចសន្យាការងារ?

## គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើចំណាកស្រុក

### គុណវិបត្តិ

- អាចទទួលរងនូវការកេងប្រវ័ញ្ចកំលាំងការងារ ការជួញដូរមនុស្សនិងការរត់ពន្ធមនុស្ស
- អាចទទួលរងការចាប់ខ្លួន ការឃុំខ្លួន និងការនិរទេសពីប្រទេសទទួល
- អាចទទួលរងនូវការរំលោភបំពានផ្សេងៗ ដូចជា ការវាយដំ ការជេរប្រមាថ ការមាក់ងាយ ការបាញ់សំលាប់ ។ល។
- អាចមានបញ្ហាសុខភាព ដូចជា ភាពតប់ប្រមល់ វិបត្តិផ្លូវចិត្ត និងការមានផ្ទៃពោះ ។ល។
- អាចទទួលរងនូវជំងឺផ្សេងៗ និងមិនទទួលបានសេវាគាំទ្រសង្គមផ្សេងៗ

### គុណសម្បត្តិ

- អាចទទួលបានប្រាក់ខែ ឬប្រាក់ឈ្នួលខ្ពស់ជាងនៅប្រទេសកំណើត
- អាចរំដោះខ្លួនចេញពីភាពក្រីក្រ ដោយមានលទ្ធភាពសន្សំលុយកាក់បានច្រើនដើម្បីផ្គត់ផ្គង់គ្រួសាររស់នៅបានសមរម្យ ព្រមទាំងមានអនាគតភ្លឺស្វាង
- ធ្វើអោយកូនមានអនាគតល្អប្រសើរដែលអាចទៅរៀន និងមានលទ្ធភាពបញ្ចប់ការសិក្សា
- អោយពលករអាចទទួលបាននូវជំនាញថ្មីៗ ដូចជា ចេះគ្រប់គ្រងពេលវេលា ចេះរៀបចំផែនការគ្រប់គ្រងថវិកា។ល។
- អាចមានលទ្ធភាពបង្កើតមុខរបរខ្នាតតូចនៅក្នុងសហាគមន៍ ?